# ទិដ្ឋភាពទូទៅ
# មូលនិធិដាំដុះ សម្រាប់គម្រោង ឆ្នាំ២០២៦
«កម្មវិធីមូលនិធិ»

## ១. តើមូលនិធិដាំដុះសម្រាប់គម្រោងមានន័យដូចម្តេច ? តើមូលនិធិនេះមានប្រតិបត្តិការដូចម្តេច ?

មូលនិធិដាំដុះសម្រាប់គម្រោង បង្កើតឡើងដើម្បីគាំទ្រសិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ សម្រាប់គាំទ្រអ្នកដែលទើបចាប់ផ្តើមការងារក្នុងគំនិតផ្តួចផ្តើម ឬពិសោធន៍គម្រោងរបស់ពួកគេ។ ពួកគេអាចស្នើសុំមូលនិធិនេះដើម្បីគាំទ្រគម្រោងទាំងមូល ឬដំណាក់កាលណាមួយនៃគម្រោងរបស់ពួកគេ។ គម្រោងទាំងនោះដូចជា៖ អភិវឌ្ឍគម្រោងច្នៃប្រឌិតថ្មីៗ គម្រោងសិល្បៈសហគមន៍ គម្រោងស្រាវជ្រាវ គម្រោងស្រាវជ្រាវទាក់ទងទៅនឹងសិល្បៈវប្បធម៌កម្ពុជា។

គោលបំណងរយៈពេលវែងនៃ មូលនិធិ គឺផ្តោតសំខាន់ជាពិសេសទៅលើ គំនិតច្នៃប្រឌិត និងភាពជាអ្នកដឹកនាំ។ មូលនិធិនេះបើកទូលាយចំពោះគ្រប់ទម្រង់សិល្បៈ លើកលែងតែសិល្បៈទស្សនីយភាព។

## ២.តើគោលដៅរបស់មូលនិធិមានអ្វីខ្លះ ?

មូលនិធិ «ដាំដុះ» សម្រាប់គម្រោងបង្កើតឡើងដើម្បីគាំទ្រដល់៖

- គម្រោងថ្មី ដែលមិនធ្លាប់មានពីមុនមក /គម្រោងសិល្បៈច្នៃប្រតិដ្ឋ
- គម្រោងសិល្បៈសហគមន៍
- គម្រោងស្រាវជ្រាវទាក់ទងទៅនឹងសិល្បៈវប្បធម៌កម្ពុជា

## ៣. តើអត្ថប្រយោជន៍នៃមូលនិធិនេះមានអ្វីខ្លះ ?

- ជួយគាំទ្រមូលនិធិគម្រោងសិល្បៈរបស់អ្នកឱ្យកើតមានឡើង
- ទទួលបានមូលនិធិរហូតដល់ ២៥០០ ដុល្លារ ដើម្បីឱ្យអ្នកអាចអនុវត្តគម្រោងបាន
- ជួយបង្កើតបណ្តាញរបស់អ្នកក្នុងសហគមន៍សិល្បៈ តាមរយៈការងាររបស់សិល្បៈខ្មែរអមតៈ
- ជួយបង្កើនភាពជាអាជីពតាមរយៈដំណើរអនុវត្តគម្រោង

## ៤. តើនរណាជាអ្នកចូលរួមគោលដៅសម្រាប់មូលនិធិនេះ ?

- សិល្បករអ្នកនិងអ្នកបម្រើការ/ប្រតិបត្តិករសិល្បៈវប្បធម៌រួមមាន៖ អ្នកដឹកនាំ និងសម្របសម្រួលកម្មវិធីសិល្បៈវប្បធម៌អ្នកស្រាវជ្រាវ និស្សិត អ្នកនិពន្ធ និងអ្នកធ្វើវិចនា ផលិតករភាពយន្ត ។ល។
- សមាជិកក្នុងសហគមន៍

ដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់មូលនិធិនេះអ្នកត្រូវ៖

- កំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា លិខិតឆ្លងដែន ឬទិដ្ឋាការ K Visa។[1]

## ៥. តើលក្ខខណ្ឌជ្រើសរើសសម្រាប់មូលនិធិនេះមានអ្វីខ្លះ?

លក្ខខណ្ឌដែលនឹងប្រើប្រាស់ដើម្បីជ្រើសរើសមូលនិធិនេះ មានដូចជា ៖

1. ត្រូវតែបំពេញពាក្យដោយប្រើទម្រង់ស្នើសុំរបស់អង្គការសិល្បៈខ្មែរអមតៈ។ សូមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចដែលបានតម្រូវឱ្យមាន។ ពាក្យស្នើសុំអាចជាភាសាខ្មែរ ឬអង់គ្លេស ឬថតចម្លើយជាវីដេអូ រឺសំឡេងក៏បាន
2. ពាក្យស្នើសុំ អាចបំពេញដោយដៃ ឬដោយកុំព្យូទ័រ។ ប្រសិនបើបេក្ខជនមានការលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមទាក់ទងមកលេខទូរស័ព្ទ ០៧៧ ៥៥ ៨៥ ៤៥ ។
3. អាចធ្វើឡើងដោយបុគ្គលម្នាក់ ឬជាក្រុម។ ក្នុងករណីជាក្រុម ត្រូវបញ្ជាក់ឈ្មោះតែប្រធានក្រុម ឬអ្នកតំណាងក្រុម។
4. ត្រូវបង្ហាញពីៈ
    - ការប្តេជ្ញាចិត្តក្នុងការអនុវត្តគម្រោងរបស់ខ្លួន
    - ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន, ប្រវត្តិនៃការអប់រំ និងការងារក្នុងវិស័យសិល្បៈ និងវប្បធម៌
    - ចក្ខុវិស័យនៃគម្រោងរបស់ខ្លួន ថាតើវានឹងជួយដល់ការអភិវឌ្ឍវិស័យសិល្បៈវប្បធម៌ដោយរបៀបណា។

**អាទិភាព នឹងត្រូវផ្តល់ជូន ៖**

អង្គការសិល្បៈខ្មែរអមតៈលើកទឹកចិត្តដល់សហគមន៍ដែលមានសំឡេងតិចឬមមាន សហគមន៍ជនជាតិដើម អ្នកមានពិការភាព ស្ត្រី និងអ្នកដែលមិនធ្លាប់បានទទួលឱកាសទាំងនេះពីមុនមកឱ្យដាក់ពាក្យស្នើសុំ។ គួរកត់សម្គាល់ថា អាទិភាពចម្បងនឹងផ្តល់ជូនទៅកាន់បេក្ខភាពជាស្ត្រីចំនួនពីរកន្លែង។

## ៦. តើដំណើរការនៃការជ្រើសរើសសម្រាប់កម្មវិធីនេះ មានអ្វីខ្លះ ?

- នៅពេលលោកអ្នកផ្ញើពាក្យស្នើសុំមកកាន់ពួកយើង ពួកយើងនឹងបញ្ជាក់ប្រាប់វិញប្រសិនបើពួកយើងបានទទួល ។ ប្រសិនបើលោកអ្នកមិនបានទទួលដំណឹងពីពួកយើងក្នុងអំឡុងពេល ៥ ថ្ងៃនៃថ្ងៃធ្វើការទេនោះ សូមទាក់ទងមកពួកយើងម្តងទៀត ។
- បន្ទាប់កាលបរិច្ឆេទឈប់ទទួលពាក្យ ពួកយើងនឹងធ្វើការពិនិត្យមើលពាក្យស្នើសុំភ្លាមៗ ។

---

[1] បុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ មិនអាចដាក់ពាក្យស្នើសុំមូលនិធិនេះទេ។

- ពាក្យស្នើសុំទាំងអស់ដែលត្រឹមត្រូវតាមលក្ខខណ្ឌ នឹងត្រូវបានពិនិត្យម្តងទៀតដោយយោងទៅតាមលក្ខខណ្ឌនៃការជ្រើសរើសដែលបានកំណត់ខាងលើ ។
    - ការពិនិត្យមើលនេះ នឹងត្រូវបានធ្វើឡើងដោយគណៈកម្មការជ្រើសរើសឯករាជ្យចំនួនបីរូប
    - ប្រព័ន្ធផ្តល់ពិន្ទុនឹងត្រូវប្រើ ដើម្បីឱ្យការផ្ទៀងផ្ទាត់ពាក្យស្នើសុំមានភាពត្រឹមត្រូវល្អ
- បេក្ខជនដែលបានជាប់ដំណាក់កាលពិនិត្យពាក្យស្នើសុំ នឹងត្រូវបានអញ្ជើញឱ្យចូលរួមវគ្គសម្ភាសនៅចន្លោះថ្ងៃ០៤ទៅ០៦ ខែមីនាឆ្នាំ២០២៦
- បេក្ខជនទាំងអស់ នឹងទទួលដំណឹងអំពីលទ្ធផលជ្រើសរើសនៅចន្លោះថ្ងៃទី «១០ ដល់១២ ខែមីនាឆ្នាំ២០២៦»

**៧. តើគ្រោងនិងពេលរបស់មូលនិធិគឺជាអ្វី ?**

បេក្ខជននិងក្រុមដែលទទួលជ័យលាភីត្រូវតាំងចិត្តចូលរួមកម្មវិធីមូលនិធិនេះ និងទុកពេលសម្រាប់ការអនុវត្តគម្រោងនៅចន្លោះខែកុម្ភៈ ដល់ខែធ្នូ ឆ្នាំ ២០២៦។

**៨. តើនរណាជា «អ្នកសម្របសម្រួល / អ្នកប្រឹក្សា / ក្រុមការងារពាក់ព័ន្ធ» ?**

- គណៈកម្មការឯករាជ្យចំនួន៣រូបនឹងពិនិត្យលម្អិតលើរាល់ពាក្យស្នើសុំដែលបានបញ្ជូនមក និងសម្រេចជ្រើសរើសបេក្ខជនជាប់ជម្រើស។ បន្ទាប់មក ពួកគាត់នឹងសម្ភាសបេក្ខជនជាប់ជម្រើស និងដាក់ពិន្ទុ ឱ្យពួកគេយ៉ាងសុក្រិត្យនិងតម្លាភាព។

- កម្មវិធីគម្រោងមូលនិធិនេះសម្របសម្រួលដោយកញ្ញា សាយ តុលា ជាអ្នកសម្របសម្រួលកម្មវិធីមូលនិធិ និងកញ្ញា យ៉ុន សុខខន ជានាយិកាប្រតិបត្តិ។

**៩. ការសង្ខេបពីកាលបរិច្ឆេទសំខាន់ៗ**

| កាលបរិច្ឆេទ | ម៉ោង | សកម្មភាព | ទីតាំង |
|---|---|---|---|
| ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២៦ | ១១:៥៩ យប់ | ផុតកំណត់ឈប់ទទួលពាក្យ | អនឡាញ |
| ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២៦ | ម៉ោង៦:០០ ដល់ម៉ោង ៧:៣០ យប់ | វេទិកាសំណួរចម្លើយនៅអង្គការសិល្បៈខ្មែរអមតៈ និង រឺតាមរយៈ Zoom: https://us02web.zoom.us/j/8127047219?omn=88157729265 | នៅអង្គការសិល្បៈខ្មែរអមតៈ និងអនឡាញ |

| | | | |
|---|---|---|---|
| | | Meeting ID: 812 704 7219 | |
| ចន្លោះថ្ងៃទី០៤ ដល់០៦ ខែ មីនា ឆ្នាំ ២០២៦ | | កាលបរិច្ឆេទសម្ភាស | នៅអង្គការសិល្បៈខ្មែរអមតៈ ឬអនឡាញ |
| ចន្លោះថ្ងៃ១០ ដល់១២ ខែ មីនា ឆ្នាំ ២០២៦ | | កាលបរិច្ឆេទផ្តល់ដំណឹងអំពីលទ្ធផល | អនឡាញ |